# លោកឪពុកអ្នកម្តាយ

*ពាក្យ៨*

ពុកម៉ែមានគុណពន់ពេកប្រមាណ ត្រដែតក្បែរមកក្សាន្តស្មានរាប់មិនដល់
លះបង់ព្រោះកូនដូចជាប់បំណុល ខ្លួនគ្មានអ្វីសល់ក្រៅពីរូបកាយ។
ធ្វើការគ្មានទើសញើសហូរកក្លាក់ រាងកាយទ្រោមបាក់ចុកឈឺសុសសាយ
ទឹកមិនច្បាស់ទឹកបាយមិនច្បាស់បាយ ចម្បែងខ្វល់ខ្វាយខ្លាចកូនមិនល្អ។
ដើម្បីកូនរៀនគ្មានសោះទ្រព្យធន់ អាងលើវែកពន់គន់គិតគូត
ព្រឹកគ្មានបាយកកគ្មាននំបបរ លេបទឹកផ្សើមកបន្តកិច្ចការ។
ក្រោមថ្ងៃក្តៅហែងផ្សែងបែកព្រិចៗ ស្មៅឈើក្រៀមខ្ទេចខ្លោចទន់រូបា
ពុកម៉ែមិនរាពាពុះស្រស់ថ្លា ទោះក្តៅយ៉ាងណាក៏មិនដែលថ្ងូរ។
ភ្លៀងផ្គរត្រជាក់ធ្លាក់ខ្យល់រងារ អ្នកផងគ្រប់គ្នាគេជ្រួលជ្រកចូល
ក្នុងផ្ទះគ្រប់ប្រាណបានជួបប្រមូល មូលវង្សត្រកូលសូរសងអ៊ូជុំ។
នៅតែលោកឪពុកនិងអ្នកម្តាយ ធ្វើការញាក់កាយក្រោមផ្គររងំ
រន្ទះផ្ទងផាំងខ្ទរខ្លាំងជិតជុំ ពុកម៉ែនៅជ្រុំជ្រោយជ្រុងភ្លឺស្រែ។
ងងឹតគ្មានខែពុកម៉ែមិនមក ឃើញកូនពន្លកដេកចាំអ៊ូអែ
ដួសបាយចំណីឆីមុនពុកម៉ែ ពុកនៅមិនដែលគិតខឹងនឹងកូន។
ពេលមកដល់ផ្ទះលះលាំងដងទឹក កូនមិនបាននឹកទាំងបងទាំងប្អូន
ចោលអំបិលហាលរលាយសព្វសូន្យ មិនបន្ទោសកូនលើកដាក់ខ្លួនឯង។
រងារស្ងិតគ្រិនមិននឹកប្តូរផ្លាស់ ខោអាវស្ងួតក្រាស់ឲ្យផុតចម្បែង
ស្ងួស្លៀកទទឹកនឹកនាគិតក្រែង សួរកូនខ្វាត់ខ្វែងរឿងសូត្ររឿងរៀន។

ខ្លាចកូនទៅរៀនឃ្លាននំចំណី
ខ្លាចមេរៀនថ្មីគ្រូលក់កូនគ្មាន
ខ្លាចកូនមិនចេះបេះបោចកោះកៀន
កកាយរុករានគ្មានសល់ទុកចាយ។

ពុកឃ្លានបារីម៉ែឃ្លានម្លូស្លា
មិនហ៊ានស្ដីថាទ្រាំលាក់ក្នុងកាយ
យប់ឡើងគេងគិតរឿងជិតរឿងឆ្ងាយ
មមែរាងអាយកាយងោកងងុយ។

ព្រឹកឡើងកូនជុំទាំងស្រីទាំងប្រុស
ជួបជុំកុញកុះចោមចាំសុំលុយ
ប្រាំបីប្រាំបួនជូនជូរពុយ
លើកដៃទាលុយរោមពុកម៉ែរឹត។

ឪពុកមុខជូរនៅក្បែរជញ្ជាំង
មើលកូនភ្លឹកគាំងភាំងព្រោះខំគិត
គ្មានលុយឲ្យកូនសូន្យអស់គំនិត
ខ្មាសញាតិឆ្ងាយជិតពិតសែនហ្មងសៅ។

កូនយកលុយអស់ខ្សោះខ្លួនរលិង
ក្នុងពាងម៉ែទិញឆៃប៉ូវឡើងខ្មៅ
ទំពាំងទឹកផ្អកច្រកជ្រក់ផ្លែផ្ដៅ
លោកវេចចេញក្រៅលាក់ខ្លាចគេដឹង។

កូនគេធ្វើការនៅឯភ្នំពេញ
បុណ្យទានវិលវិញមៀងមើលសម្លឹង
ពុកម៉ែគេចមុខសំងំយំខឹង
ខ្មាសគេណាស់ប្រឹងខឲ្យកូនរៀន។

ម៉ូតូចេញថ្មីបើកដីហុយផ្អោង
គេដឹកសណ្ដោងឥតខ្មាស់ឥតអៀន
ខោអាវទុយនុយលុយចាយក៏មាន
ប្លែកតែអ្នករៀនគ្មានសល់អ្វីសោះ។

រៀនយូរិតតែបែជាក្រីក្រ
ខ្វះស្រូវអង្កររស់ដោយក្រៀមក្រោះ
មានតែចំណេះម្ល៉េះលុយបាត់អស់
មិនអាចលោតផ្លោះមកអួតអាងបាន។

តែពុកនិងម៉ែនៅសើចញញឹម
ផ្ដល់ក្ដីសង្ឃឹមដល់កូនគ្រប់ប្រាណ
កក់ក្ដៅសុខុមត្រជុំស្រាកស្រាន្ត
មង្គលកើតបានដោយក្ដីមេត្តា។

*ស្រីសន្ធរ ៣០ មករា ១៩៩៩*

*សួយ ឡូត*